00879285 E256/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jan-2013, 08:32
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ១៨ មករា ឆ្នាំ ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ អៀង សារី (អនុសាសន៍) ទាក់ទងនឹងវិសាលភាពនៃការពិនិត្យសុខភាពនៅខែ មីនា ឆ្នាំ ២០១៣ ដោយសាស្ត្រាចារ្យ A. JOHN CAMPBELL វេជ្ជបណ្ឌិត SEENA FAZEL និង វេជ្ជបណ្ឌិត ហួត លីនណា**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្ដី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន÷**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង÷**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ចៅក្រមបម្រុង **ធូ មន្នី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

យោងតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការតែងតាំងអ្នកជំនាញជាថ្មីឡើងវិញដើម្បីពិនិត្យសុខភាព និងសម្បទារបស់ អៀង សារី និង នួន ជា ក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣[១]" តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") លោក អៀង សារី សូមដាក់ជូនអនុសាសន៍ដូចខាងក្រោមនេះ។ សំណើទាំងនេះ *មិនត្រូវ* ចាត់ទុកថា ជាការបដិសេធទឡ្ហីករណ៍ដែលបានលើកឡើងពីមុនៗ ពាក់ព័ន្ធនឹងតម្រូវការឲ្យមានអ្នកជំនាញបន្ថែមច្រើនរូបទៀតដើម្បី ពិនិត្យសម្បទារបស់លោក អៀង សារី នោះទេ។ មេធាវីការពារក្តីបានប្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា លោក អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងថា ការតែងតាំងអ្នកជំនាញបន្ថែមមិនមែនជាការចាំបាច់នោះទេ[២]។ មេធាវីការពារក្តីសូមអះអាងថា សាស្ត្រាចារ្យ Campbell មិនមានសមត្ថភាពនោះទេ ហើយការពិនិត្យសុខភាពដោយអ្នកជំនាញទាំងនេះ មិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីជួយឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចទៅលើសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមសវនាការបានទេ។

## អនុសាសន៍

១. ដើម្បីវាយតម្លៃឲ្យបានហ្មត់ចត់ទៅលើសុខភាព និងសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមក្នុងសវនាការ អ្នកជំនាញគួរតែធ្វើការពិនិត្យសុខភាពលោក អៀង សារី នៅក្នុងសវនាការយ៉ាងតិចបំផុតឲ្យបានប្រាំថ្ងៃ។ យោងតាមវេជ្ជបណ្ឌិត Harold Bursztajn ដែលមានជំនាញខាងកោសលវិច័យប្រសាទសាស្ត្រ និងវិកលវិទ្យា រយៈពេលជាអប្បរមានេះគឺជាការចាំបាច់ "ដោយសារតែភាពស្មុគស្មាញនៃការវាយតម្លៃ និងបញ្ហាចម្បងៗ ដូចជា ការអស់កម្លាំងរហិតរហៃ

---

[១] ការតែងតាំងអ្នកជំនាញជាថ្មីឡើងវិញដើម្បីពិនិត្យសុខភាព និងសម្បទារបស់ អៀង សារី និង នួន ជា ក្នុងអំឡុងសប្តាហ៍ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E256។

[២] ជាឧទាហរណ៍ *សូមមើល* បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការតែងតាំងអ្នកជំនាញបន្ថែមដើម្បីវាយតម្លៃសម្បទារបស់គាត់ ចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E238/9/2/1។

និងសុខភាពខួរក្បាលដែលមានការប្រែប្រួលមិនទៀងទាត់ ... ”។[៣]

២. យោងតាមវេជ្ជបណ្ឌិត Bursztajn ជាផ្នែកមួយនៃការពិនិត្យសុខភាព អ្នកជំនាញទាំងនេះគួរតែៈ

ក. ព្យាយាមយល់ដឹងអំពីដំណើរការនីតិវិធីដើម្បីវាយតម្លៃថាតើលោក អៀង សារី អាចតាមដានដំណើរការនីតិវិធីបានគ្រប់គ្រាន់ ដើម្បីជួយដល់មេធាវីការពារក្ដីដែរឬយ៉ាងណា។

ខ. ពិនិត្យតាមដានលោក អៀង សារី នៅក្នុងសាលសវនាការ ឬនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោមក្នុងរយៈពេលមួយ។

គ. ពិនិត្យតាមដានការទំនាក់ទំនងរវាងមេធាវី និងកូនក្ដី។

ឃ. ពិនិត្យប្រវត្តិផ្នែកវេជ្ជសាស្ត្រ និងប្រវត្តិសុខភាពផ្នែកស្មារតីឲ្យបានហ្មត់ចត់ និងពិចារណាអំពីការជាប់ទាក់ទងរវាងការចុះអន់ថយផ្នែកសុខភាព និងការចុះអន់ថយផ្នែកប្រព័ន្ធប្រសាទសាស្ត្រ។

ង. ពិចារណាទៅលើប្រវត្តិរបស់លោក អៀង សារី ទាក់ទងនឹងទាក់ទងទៅនឹងរបៀបរបប (ផ្នែកវប្បធម៌) នៃការជំនុំជម្រះ។

ច. ធ្វើការសម្ភាសន៍ផ្នែកកោសលវិច័យប្រសាទសាស្ត្រជាលក្ខណៈប្រព័ន្ធ (ប្រសិនបើអ្នកជំនាញណាម្នាក់មានជំនាញលើផ្នែកនេះ)។

ឆ. ធ្វើការវាយតម្លៃឲ្យបានហ្មត់ចត់ទៅលើកម្រិតរបស់លោក អៀង សារី ក្នុងការយកចិត្តទុកដាក់ ការផ្ដង់អារម្មណ៍ ការយល់ដឹង និងការប្រាស្រ័យទាក់ទងអំពីភាសាដែលពាក់ព័ន្ធ និងមុខងារប្រតិបត្តិការ ដោយប្រៀបទៅនឹងការអំណត់របស់គាត់ក្នុងពេលមានការអស់កម្លាំង និងឈឺចាប់ នៅពេលដែលសវនាការកំពុងបន្តដំណើរការ និងកំណើនភាពស្មុគស្មាញនៃព័ត៌មានដែលផ្ដល់ឲ្យគាត់។

ជ. ធ្វើការពិនិត្យទៅលើស្ថានភាពផ្នែកសមត្ថភាពផ្នែកស្មារតីជាក់លាក់ ពាក់ព័ន្ធនឹងសមត្ថភាព

[៣] លិខិតរបស់វេជ្ជបណ្ឌិត Bursztajn ផ្ញើជូនមេធាវីការពារក្ដី ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E238/11.3។

ជួយដល់មេធាវីការពារក្តី ដែលក្នុងនោះរួមមាន ជាឧទាហរណ៍ ការវាយតម្លៃទៅលើការចងចាំអំពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់។ សមត្ថភាពនេះ ត្រូវតែវាយតម្លៃដោយផ្អែកលើវិធីសាស្ត្រដែលប្រើបរិបទ និងកិច្ចការជាក់លាក់ (ជាជាងការវាយតម្លៃក្នុងលក្ខណៈទូទៅ)។

ឈ. ធានាថាជនជាប់ចោទមិនមានការក្លែងបន្លំ ការបំផ្លើស ឬការធ្វើពុត។

ញ. វាយតម្លៃអំពីផលប៉ះពាល់ចម្បងៗដោយការប្រើប្រាស់ថ្នាំដ៏ច្រើន ទោះជាផលប៉ះពាល់នោះកើតមានខ្លាំង ឬកើតមានជាបណ្តើរៗ ដោយមិនបញ្ចេញរូបរាងច្បាស់ ប៉ុន្តែ ប៉ះពាល់ខ្លាំងដល់ប្រព័ន្ធប្រសាទ។

ដ. ពិនិត្យឡើងវិញ និងវិភាគទៅលើរបាយការណ៍វេជ្ជសាស្ត្រពាក់ព័ន្ធទាំងអស់។

ឋ. ពិចារណាទៅលើទិន្នន័យពាក់ព័ន្ធ ដែលជាប់ទាក់ទងទៅនឹងការវាយតម្លៃនេះ[៤]។

៣. ការព្រួយបារម្ភចម្បងរបស់មេធាវីការពារក្តីទៅលើរបាយការណ៍មុនៗ ដែលបានរៀបចំឡើងរួមគ្នាដោយដោយសាស្ត្រាចារ្យ Campbell វេជ្ជបណ្ឌិត Fazel និង វេជ្ជបណ្ឌិត ហួត លីនណា[៥] គឺថារបាយការណ៍នោះញែកដាច់ពីគ្នាទាំងស្រុងរវាងការវាយតម្លៃលើសុខភាពផ្លូវចិត្ត និងការវាយតម្លៃលើសុខភាពរាងកាយរបស់លោក អៀង សារី[៦]។ ដើម្បីដោះស្រាយភាពខ្វះចន្លោះនេះ នៅក្នុងចំណោម*បញ្ហាជាច្រើន* អ្នកជំនាញត្រូវពិចារណាអំពី៖

ក. សមត្ថភាពរបស់លោក អៀង សារី ក្នុងការផ្តង់អារម្មណ៍ទៅលើដំណើរការនីតិវិធី នៅពេលដែលគាត់មានអស់កម្លាំងខ្លាំង វិលមុខ ចង់ក្អួត ឈឺចុកចាប់ ឬដេកលក់។

---

[៤] អនុសាសន៍ទាំងនេះ ត្រូវបានស្នើឡើងដោយវេជ្ជបណ្ឌិត Bursztajn។ *សូមមើល លេខជើងទំព័រយោងខាងលើ*។

[៥] របាយការណ៍វេជ្ជសាស្ត្រអំពីសុខភាពលោក អៀង សារី ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E222/1។

[៦] *សូមមើល* បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការតែងតាំងអ្នកជំនាញបន្ថែមដើម្បីវាយតម្លៃសម្បទារបស់គាត់ ចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E238/9/2/1 កថាខណ្ឌ ៤៣។ សំណើរបស់ អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលសម្រេចថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងចូលរួមសវនាការ និងការបដិសេធសំណើរបស់សុំឱ្យតែងតាំងអ្នកជំនាញម្នាក់បន្ថែមទៀត ដើម្បីជួយក្នុងការកំណត់អំពីសម្បទារបស់គាត់ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E238/11កថាខណ្ឌ ៣០ ដល់ ៣១។

ខ. ថាតើលោក អៀង សារី អាចចងចាំសក្ខីកម្មរបស់សាក្សីបានដែរឬអត់ នៅពេល (ឬក្រោយពេល) អស់កម្លាំងខ្លាំង វិលមុខ ចង់ក្អួត ឈឺចុកចាប់ ឬដេកលក់។

គ. ថាតើលោក អៀង សារី អាចមានលទ្ធភាពតាមដានដំណើរការនីតិវិធីបានពេញលេញដែរឬអត់ ពេល (ឬក្រោយពេល) អស់កម្លាំង វិលមុខ ចង់ក្អួត ឈឺចុកចាប់ ឬដេកលក់។

៤. ដើម្បីធ្វើការសម្រេចទាំងនេះបាន និងក្នុងការរក្សាតម្លាភាព អ្នកជំនាញគួរតែបញ្ចូលព័ត៌មានខាងក្រោមទៅក្នុងរបាយការណ៍របស់ខ្លួន៖

ក. ថាតើ (និងរយៈពេលប៉ុន្មាន) ដែលលោក អៀង សារី សម្រាន្តលក់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី។

ខ. តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យលោក អៀង សារី សម្រាន្តលក់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី។

គ. តើការសម្រាន្តលក់ជះឥទ្ធិពលយ៉ាងណាដល់សមត្ថភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី។

ឃ. តើលោក អៀង សារី ឧស្សាហ៍វិលមុខញឹកញាប់បែបណា ហើយតើការវិលមុខម្តងៗមានរយៈពេលប៉ុន្មាន។

ង. ថាតើ និងរយៈពេលប៉ុន្មានដែលលោក អៀង សារី មានអារម្មណ៍ចង់ក្អួត ដោយសារការវិលមុខ ឬដោយសារមូលហេតុផ្សេងៗទៀត។

ច. តើការវិលមុខ ឬចង់ក្អួត ជះឥទ្ធិពលយ៉ាងណា ដល់សមត្ថភាពរបស់លោក អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី។

ឆ. តើលោក អៀង សារី អាចដេកចុះដោយពុំចាំបាច់ប្រែខ្លួនចុះឡើងរយៈពេលប៉ុន្មាន ដោយសារមិនស្រួលខ្លួន ឬដោយសារការឈឺចុកចាប់។

ជ. តើលោក អៀង សារី ត្រូវប្រែខ្លួនចុះឡើងៗញឹកញាប់បែបណា ដោយសារមិនស្រួលខ្លួន ឬដោយសារការឈឺចុកចាប់។

ឈ. តើការប្រែខ្លួនចុះឡើងជះឥទ្ធិពលយ៉ាងណាដល់សមត្ថភាពរបស់លោក អៀង សារី ក្នុង

ការតាមដានកិច្ចដំណើរការនីតិវិធី ជាពិសេសនៅពេលដែលត្រូវតាមដានកិច្ចដំណើរការនីតិវិធីតាមអេក្រង់ទូរទស្សន៍។

ញ. តើជារៀងរាល់ថ្ងៃ លោក អៀង សារី ត្រូវមើលអេក្រង់ទូរទស្សន៍ញឹកញាប់បែបណា។ និង

ដ. ថាតើ និងក្នុងកម្រិតពិស្តារបែបណា ដែលលោក អៀង សារី អាចរៀបរាប់បានពីអ្វីដែលបានកើតឡើងនៅក្នុងតុលាការនៅថ្ងៃដដែល ឬនៅប៉ុន្មានថ្ងៃមុន។

៥. ដើម្បីធានាតម្លាភាពក្នុងកម្រិតអតិបរិមាជាបន្តទៀត ជាពិសេស ប្រសិនបើអ្នកជំនាញទាំងឡាយណាដែលអាចត្រូវបានជ្រើសរើសឲ្យមកពិនិត្យលោក អៀងសារី នាពេលអនាគតនោះ របាយការណ៍គួររួមបញ្ចូលព័ត៌មានដូចខាងក្រោម៖

ក. បញ្ជីឯកសារវេជ្ជសាស្ត្រទាំងអស់ដែលធ្លាប់បានពិនិត្យ។

ខ. បញ្ជីឯកសារស្រាវជ្រាវទាំងឡាយណាដែលធ្លាប់បានពិនិត្យឡើងវិញ និង/ឬ ដែលធ្លាប់បានយកមកធ្វើជាមូលដ្ឋាន។

គ. បញ្ជី និងការពន្យល់របស់វេជ្ជបណ្ឌិតផ្សេងទៀតដែលធ្លាប់បានពិគ្រោះយោបល់។

ឃ. ការពន្យល់លម្អិតស្តីពីការពិនិត្យដែលធ្លាប់បានធ្វើឡើង។

ង. បញ្ជីនៃការធ្វើតេស្តដែលធ្លាប់បានធ្វើឡើង។ និង

ច. បញ្ជីនៃការធ្វើតេស្តដែលពុំទាន់បានធ្វើឡើង ហើយជាធម្មតាការធ្វើតេស្តទាំងនេះត្រូវធ្វើឡើងនៅក្នុងអំឡុងពេលវាយតម្លៃបែបនេះ ព្រមទាំងការពន្យល់អំពីមូលហេតុដែលត្រូវធ្វើតេស្តទាំងនេះ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលទាំងអស់ដូចបានរៀបរាប់នៅក្នុងសំណើសុំនេះ ក្រុមមេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះ៖

ក. **ទទួលយក**អនុសាសន៍ទាំងនេះពាក់ព័ន្ធនឹងវិសាលភាពនៃការវាយតម្លៃវេជ្ជសាស្ត្រ និង

ខ. **បង្គាប់**សាស្ត្រាចារ្យ Campbell និងវេជ្ជបណ្ឌិត Fazel និង ហ្វូត លីណា អនុវត្តតាមអនុសាសន៍ទាំងនេះដោយគ្មានចំណុចលើកលែង។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលនូវការគោរពពីសហមេធាវីការពារក្តីរបស់លោក អៀង សារី៖

ធ្វើនៅរាជធានីភ្នំពេញក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី **១៨** ខែ **មករា ឆ្នាំ ២០១៣។**

__________________ ______________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តីរបស់លោក អៀង សារី